ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ទីស្តីការគណៈរដ្ឋមន្ត្រី

លេខ : ០៤ សសរ

# សេចក្តីសម្រេច

## ស្តីពី

## ការបង្កើតអនុគណៈកម្មការចំពោះកិច្ចចាក់វ៉ាក់សាំងកូវីដ-១៩ នៅទីស្តីការគណៈរដ្ឋមន្ត្រី

### ឧបនាយករដ្ឋមន្ត្រីប្រចាំការ រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣២០/៤២១ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២០ ស្តីពីការតែងតាំងនិងកែសម្រួលសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៣២១/០០៤ ចុះថ្ងៃទី១១ ខែមីនា ឆ្នាំ២០២១ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីវិធានការទប់ស្កាត់ការឆ្លងរាលដាលនៃជំងឺកូវីដ-១៩ និងជំងឺឆ្លងកាចសាហាវនិងប្រកបដោយគ្រោះថ្នាក់ធ្ងន់ធ្ងរផ្សេងទៀត
- បានឃើញអនុក្រឹត្យលេខ១១៦ អនក្រ.បក ចុះថ្ងៃទី៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃទីស្តីការគណៈរដ្ឋមន្ត្រី
- បានឃើញអនុក្រឹត្យលេខ៣៧ អនក្រ.បក ចុះថ្ងៃទី១២ ខែមីនា ឆ្នាំ២០២១ ស្តីពីវិធានការសុខាភិបាលដើម្បីទប់ស្កាត់ការឆ្លងរាលដាលនៃជំងឺកូវីដ-១៩ និងជំងឺឆ្លងកាចសាហាវនិងប្រកបដោយគ្រោះថ្នាក់ធ្ងន់ធ្ងរផ្សេងទៀត
- បានឃើញសេចក្តីសម្រេចលេខ៣៧ សសរ ចុះថ្ងៃទី១៧ ខែមីនា ឆ្នាំ២០២១ ស្តីពីការបង្កើតគណៈកម្មការចំពោះកិច្ចចាក់វ៉ាក់សាំងកូវីដ-១៩ ក្នុងក្របខណ្ឌទូទាំងប្រទេស
- យោងតាមការចាំបាច់

## សម្រេច

**ប្រការ១.-**

បង្កើតអនុគណៈកម្មការចំពោះកិច្ចចាក់វ៉ាក់សាំងកូវីដ-១៩ នៅទីស្តីការគណៈរដ្ឋមន្ត្រី ដែលមានសមាសភាពដូចខាងក្រោម៖

| | | | |
|---|---|---|---|
| ១. ឯកឧត្តម | **សយ សុខា** | រដ្ឋលេខាធិការ | ប្រធាន |
| ២. ឯកឧត្តម | **អេង កុកថាយ** | អនុរដ្ឋលេខាធិការ | អនុប្រធាន |

| | | | |
|---|---|---|---|
| ៣.ឯកឧត្តម | **សូ សុខ** | នាយករងខុទ្ទកាល័យឯកឧត្តមកិត្តិនីតិកោសលបណ្ឌិត ឧបនាយករដ្ឋមន្ត្រីប្រចាំការ រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី | សមាជិក |
| ៤.ឯកឧត្តម | **ឈុន ថុន** | អគ្គនាយកនៃអគ្គនាយកដ្ឋានរដ្ឋបាលនិងហិរញ្ញវត្ថុ | សមាជិក |
| ៥.ឯកឧត្តម | **អ៊ុំ សម្បូរណ៍** | អគ្គនាយកនៃអគ្គនាយកដ្ឋានសម្របសម្រួលកិច្ចការទូទៅ | សមាជិក |
| ៦.លោកជំទាវ | **ហ៊ាន ម៉ូលីណោ** | អគ្គនាយកនៃអគ្គនាយកដ្ឋានសហប្រតិបត្តិការអន្តរជាតិ | សមាជិកា |
| ៧.ឯកឧត្តម | **រិទ្ធ អរុណវិទ្យា** | អគ្គនាយកនៃអគ្គនាយកដ្ឋានសម្របសម្រួលកិច្ចការផ្ទៃក្នុង | សមាជិក |
| ៨.ឯកឧត្តម | **ឆាំង ហ៊ុយ** | អគ្គនាយកនៃអគ្គនាយកដ្ឋានសេដ្ឋកិច្ចនិងទេសចរណ៍ | សមាជិក |
| ៩.ឯកឧត្តម | **ថោង សុគន្ធ** | អគ្គនាយកនៃអគ្គនាយកដ្ឋានកិច្ចការសង្គម | សមាជិក |
| ១០.ឯកឧត្តម | **ឡុង សុខា** | អគ្គនាយកនៃអគ្គនាយកដ្ឋានផលិតកម្ម រៀបចំដែនដី នគរូបនីយកម្ម និងសំណង់ | សមាជិក |
| ១១.លោកជំទាវ | **ខិន ផលរ័ត្ន** | អគ្គនាយកនៃអគ្គនាយកដ្ឋានរាជកិច្ចនិងតម្កល់ឯកសារជាតិ | សមាជិកា |
| ១២.ឯកឧត្តម | **អ៊ឹម ស៊ីថុល** | អគ្គលេខាធិការក្រុមប្រឹក្សាអ្នកច្បាប់ | សមាជិក |
| ១៣.ឯកឧត្តម | **សុខ ស៊ីឡូ** | អគ្គលេខាធិការក្រុមប្រឹក្សាស្តារអភិវឌ្ឍន៍វិស័យកសិកម្ម និងជនបទ | សមាជិក |
| ១៤.ឯកឧត្តម | **ព្រំ សុគមង្គល** | អគ្គលេខាធិការអាជ្ញាធរកម្ពុជាគ្រប់គ្រងសកម្មភាពកំចាត់មីន និងសង្គ្រោះជនពិការដោយសារមីន | សមាជិក |
| ១៥.ឯកឧត្តម | **ម៉ៃ សំបូរ** | អគ្គលេខាធិការវេទិកាសម្ព័ន្ធសង្គមស៊ីវិល | សមាជិក |
| ១៦.ឯកឧត្តម | **យង់ ពៅ** | អគ្គលេខាធិការរាជបណ្ឌិត្យសភាកម្ពុជា | សមាជិក |
| ១៧.ឯកឧត្តម | **ទិត សុធា** | អនុប្រធានអង្គភាពព័ត៌មាន និងប្រតិកម្មរហ័ស | សមាជិក |
| ១៨.ឯកឧត្តម | **គឹម នាន** | អនុប្រធានលេខាធិការដ្ឋាននៃគណៈកម្មាធិការជាតិប្រឆាំងភេរវកម្ម | សមាជិក |
| ១៩.ឯកឧត្តម | **ម៉ិច សុខា** | អគ្គលេខាធិការរងក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ | សមាជិក |
| ២០.ឯកឧត្តម | **ផល សុជាតិ** | អគ្គលេខាធិការរងគណៈកម្មាធិការជាតិជំរុញចលនាភូមិមួយផលិតផលមួយ | សមាជិក |
| ២១.ឯកឧត្តម | **ជា ប្រណិត** | អគ្គលេខាធិការរងគណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ | សមាជិក |
| ២២.ឯកឧត្តម | **ណែត ភឿត** | អគ្គលេខាធិការរងគណៈកម្មាធិការជាតិរៀបចំបុណ្យជាតិ-អន្តរជាតិ | សមាជិក |
| ២៣.លោកជំទាវ | **អ៊ុច និពន្ធ** | អគ្គនាយកនៃអគ្គនាយកដ្ឋានរដ្ឋបាលនិងពាក្យបណ្តឹងនៃគណៈកម្មាធិការសិទ្ធិមនុស្សកម្ពុជា | សមាជិកា |
| ២៤.ឯកឧត្តម | **ឯក ថា** | អនុប្រធានប្រចាំការអង្គភាពអ្នកនាំពាក្យរាជរដ្ឋាភិបាល | សមាជិក |
| ២៥.ឯកឧត្តម | **កុយ ទិសុទ្ធ** | ប្រធាននាយកដ្ឋានរដ្ឋបាល និងហិរញ្ញកិច្ចនៃលេខាធិការដ្ឋានអចិន្ត្រៃយ៍អាជ្ញាធរជាតិទទួលបន្ទុកកិច្ចការព្រំដែន | សមាជិក |

| | | | |
|---|---|---|---|
| ២៦.ឯកឧត្តម | **រស្មី ឧត្តម** | សមាជិកក្រុមលេខាសម្តេចតេជោ នាយករដ្ឋមន្ត្រី | សមាជិក |
| ២៧.លោក | **ពៅ ចាន់មុនីផល** | ប្រធាននាយកដ្ឋានបុគ្គលិក នៃអគ្គនាយកដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុ | សមាជិក។ |

**ប្រការ២.-**

អនុគណៈកម្មការនេះ មានភារកិច្ចដូចតទៅ៖

- សហការជាមួយគណៈកម្មការចំពោះកិច្ចចាក់វ៉ាក់សាំងកូវីដ-១៩ ក្នុងក្របខណ្ឌទូទាំងប្រទេស ដើម្បីសម្របសម្រួលការចាក់វ៉ាក់សាំងកូវីដ-១៩ ជូនថ្នាក់ដឹកនាំ មន្ត្រីរាជការ និងមន្ត្រីជាប់កិច្ចសន្យានៃទីស្តីការគណៈរដ្ឋមន្ត្រី
- រៀបចំបញ្ជីឈ្មោះថ្នាក់ដឹកនាំ មន្ត្រីរាជការ និងមន្ត្រីជាប់កិច្ចសន្យានៃទីស្តីការគណៈរដ្ឋមន្ត្រី ដែលស្ម័គ្រចិត្តចាក់វ៉ាក់សាំងកូវីដ-១៩
- តាមដាននិងធ្វើរបាយការណ៍វឌ្ឍនភាពការងារចាក់វ៉ាក់សាំងប្រចាំថ្ងៃជូនឯកឧត្តមកិត្តិនីតិកោសលបណ្ឌិត ឧបនាយករដ្ឋមន្ត្រីប្រចាំការ រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និងគណៈកម្មការចំពោះកិច្ចចាក់វ៉ាក់សាំងកូវីដ-១៩
- បំពេញភារកិច្ចផ្សេងៗទៀតពាក់ព័ន្ធនឹងការងារចាក់វ៉ាក់សាំងកូវីដ-១៩។

**ប្រការ៣.-**

អគ្គនាយកនៃអគ្គនាយកដ្ឋានរដ្ឋបាលនិងហិរញ្ញវត្ថុ ប្រធាននាយកដ្ឋានបុគ្គលិក ប្រធាននាយកដ្ឋានផ្គត់ផ្គង់និងហិរញ្ញវត្ថុ និងសាមីខ្លួនដូចមានចែងក្នុងប្រការ១ ត្រូវទទួលបន្ទុកអនុវត្តសេចក្តីសម្រេចនេះតាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃ សុក្រ ១៤កើត ខែ ចេត្រ ឆ្នាំជូត ទោស័ក ព.ស.២៥៦៤

រាជធានីភ្នំពេញ ថ្ងៃទី ២៦ ខែ មីនា ឆ្នាំ២០២១

**ឧបនាយករដ្ឋមន្ត្រីប្រចាំការ**

**រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី**

កិត្តិនីតិកោសលបណ្ឌិត **ប៊ិន ឈិន**

**កន្លែងទទួល :**

- ក្រសួងសុខាភិបាល
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រី
- គណៈកម្មការចំពោះកិច្ចចាក់វ៉ាក់សាំងកូវីដ-១៩ ក្នុងក្របខណ្ឌទូទាំងប្រទេស
- ដូចប្រការ៣
- ឯកសារ កាលប្បវត្តិ